**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៦ ស.ច.

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់សមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ ដែលត្រូវបាន បង្កើតឡើងដោយមាត្រា៣៥២ នៃច្បាប់ស្តីពីការងារ និងដែលមានបេសកកម្មជាអាទិ៍ សិក្សាស្រាវជ្រាវរាល់បញ្ហាដែលទាក់ទងនឹងការងារមុខរបរនៃកម្មករនិយោជិត ប្រាក់ឈ្នួល ការអប់រំវិជ្ជាជីវៈ ចលនាកម្លាំងពលកម្មក្នុងប្រទេស ទេសន្តរប្រវេសន៍ ការរៀបចំអោយរឹតតែប្រសើរឡើងនូវល័ក្ខខ័ណ្ឌខាងសម្ភារៈ និងខាងស្មារតី នៃកម្មករនិយោជិត ហើយនិងបញ្ហាអនាម័យ និងសន្តិសុខការងារ ។

គណៈកម្មការប្រឹក្សាការងារមានភារកិច្ចជាអាទិ៍ដូចតទៅ ÷

- លើកយោបល់ណែនាំអំពីអត្រាប្រៀវត្សអប្បបរមា ដែលត្រូវធានា
- ផ្តល់យោបល់ជាមុន ដើម្បីពង្រីកដែនអនុវត្តអនុសញ្ញារួម ឬក្នុងករណីដែលគ្មានអនុសញ្ញារួមទេ ផ្តល់យោបល់ជាយថាហេតុជាមុន ចំពោះបទបញ្ជានៃល័ក្ខខ័ណ្ឌមុខរបរនៅក្នុងវិជ្ជាជីវៈមួយ ឬក្នុងវិស័យសកម្មភាពណាមួយជាក់លាក់ ។

## ជំពូកទី ២

## សមាសភាពនៃគណៈកម្មការប្រឹក្សាការងារ

**មាត្រា ២.-**

គណៈកម្មការប្រឹក្សាការងារមានសមាសភាពដូចតទៅ ÷

- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង មួយ(០១) រូប ជាប្រធាន
- តំណាងអង្គការសហជីពកម្មករនិយោជិតដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ មួយ(០១) រូប ជាអនុប្រធាន
- តំណាងអង្គការនិយោជកដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ មួយ(០១) រូប ជាអនុប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម មួយ(០១) រូប ជាសមាជិក ៸.៸.

- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងសុខាភិបាល មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងកិច្ចការនារី មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងបរិស្ថាន មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងមហាផ្ទៃ មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងទេសចរណ៍ មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងយុត្តិធម៌ មួយ(០១) រូប ជាសមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មួយ(០១) រូប ជាសមាជិក
- តំណាងអង្គការសហជីពកម្មករនិយោជិតដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិចំនួន ប្រាំមួយ(០៦) រូប ជាសមាជិក
- តំណាងអង្គការនិយោជកដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិចំនួន ប្រាំមួយ(០៦) រូប ជាសមាជិក ។

គណៈកម្មការនេះ ត្រូវបោះឆ្នោតជ្រើសរើសអនុប្រធានពីររូប គឺម្នាក់ក្នុងចំណោម ៧នាក់ ដែលជាតំណាងនៃអង្គការសហជីពកម្មករនិយោជិត ដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ និងម្នាក់ទៀតក្នុងចំណោម ៧នាក់ ដែលតំណាងអង្គការនិយោជកដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ ។

នីតិវិធីនៃការបោះឆ្នោតជ្រើសរើសអនុប្រធានគណៈកម្មការប្រឹក្សាការងារត្រូវអនុវត្តដូចតទៅ ÷

-ដោយបានទទួលសិទ្ធិពីគណៈកម្មការប្រឹក្សាការងារក្នុងកិច្ចប្រជុំ សមាជិកទាំង៧រូប នៃភាគីតំណាងអង្គការសហជីពកម្មករនិយោជិត ដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ បោះឆ្នោតជ្រើសរើសអនុប្រធានមួយរូបនៃគណៈកម្មការប្រឹក្សាការងារ ។

-ដោយបានទទួលសិទ្ធិពីគណៈកម្មការប្រឹក្សាការងារក្នុងកិច្ចប្រជុំ សមាជិកទាំង៧រូប នៃភាគីតំណាងអង្គការនិយោជកដែលមាន ភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ បោះឆ្នោតជ្រើសរើសអនុប្រធានមួយរូបនៃគណៈកម្មការប្រឹក្សាការងារ ។

គណៈកម្មការប្រឹក្សាការងារត្រូវមានសមាជិកបម្រុងដែលមានចំនួនស្មើនឹងចំនួនសមាជិកពេញសិទ្ធិ ។ ៚

**មាត្រា ៣.-**

ឈ្មោះសមាជិកពេញសិទ្ធិ និងឈ្មោះសមាជិកបម្រុងរបស់គណៈកម្មការប្រឹក្សាការងារ ដែលឧទ្ទេសនាម ដោយក្រសួងពាក់ព័ន្ធ ដោយអង្គការសហជីពកម្មករនិយោជិត និងដោយអង្គការនិយោជក ត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ

**មាត្រា ៤.-**

លើកលែងតែប្រធានគណៈកម្មការដែលជារដ្ឋមន្ត្រី សមាជិកគណៈកម្មការប្រឹក្សាការងារមានអាណត្តិមួយ ឆ្នាំ ហើយអាចបន្តទៀតបានតាមការចាត់តាំងពីក្រសួង ស្ថាប័ន ឬអង្គការពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា២ នៃ អនុក្រឹត្យនេះ ។ គណៈកម្មការប្រឹក្សាការងារត្រូវដំណើរការការងារនៅក្នុងអាណត្តិរបស់ខ្លួន រហូតដល់មានការ ប្រកាសតែងតាំងសមាសភាពនៃគណៈកម្មការនេះសម្រាប់អាណត្តិថ្មីមកជំនួស ។

**មាត្រា ៥.-**

ករណីដែលសមាជិកពេញសិទ្ធិទទួលមរណភាព លាឈប់ ត្រូវបានដកហូត ឬផ្លាស់ប្តូរពីតំណែង ដោយ ប្រការណាមួយ ដោយក្រសួង ស្ថាប័ន ឬអង្គការពាក់ព័ន្ធ សមាជិកបម្រុងដែលមកពីក្រសួង ស្ថាប័ន ឬអង្គការ ពាក់ព័ន្ធនោះនឹងក្លាយជាសមាជិកពេញសិទ្ធិដោយស្វ័យប្រវត្តិរហូតដល់ចប់អាណត្តិ ។ ក្នុងរយៈពេលនេះ ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចស្នើអោយក្រសួង ឬអង្គការពាក់ព័ន្ធ ឧទ្ទេសនាមបេក្ខជនថ្មីជំនួសសមាជិក បម្រុងមុនបើពិនិត្យឃើញថាចាំបាច់ ។

**មាត្រា ៦.-**

គណៈកម្មការប្រឹក្សាការងារត្រូវរួមប្រជុំពីរដងយ៉ាងតិច ក្នុងមួយឆ្នាំ ។ ប្រធានគណៈកម្មការប្រឹក្សា ការងារអាចកោះប្រជុំគណៈកម្មការនេះបានគ្រប់ពេល ទៅតាមការយល់ឃើញរបស់ខ្លួន ឬទៅតាមសំណើរបស់ អនុប្រធានណាមួយ ។ សំណើនេះត្រូវបញ្ជាក់ពីហេតុផលសមស្រប និងការចាំបាច់ ។ ក្នុងករណីឯកភាព ប្រធាន គណៈកម្មការត្រូវរៀបចំរបៀបវារៈនៃសម័យប្រជុំ ដោយពិគ្រោះយោបល់ជាមួយអនុប្រធានទាំងពីរ ។ ការប្រជុំ ត្រូវធ្វើក្នុងអំឡុង ៣០(សាមសិប)ថ្ងៃ យ៉ាងយូរ ក្រោយការរៀបចំរបៀបវារៈ ។ ក្នុងករណីដែលសមាជិកពេញ សិទ្ធិអវត្តមាន សមាជិកបម្រុងត្រូវចូលរួមប្រជុំជំនួស ។ល។

លិខិតអញ្ជើញចូលរួមប្រជុំ និងឯកសារត្រៀមត្រូវផ្ញើជូនសមាជិកពេញសិទ្ធិ និងសមាជិកបម្រុងយ៉ាងយឺតបំផុត ១៥ (ដប់ប្រាំ) ថ្ងៃមុនសម័យប្រជុំ ។

**មាត្រា ៧.-**

ការបោះឆ្នោតត្រូវធ្វើឡើងតាមបទបញ្ជាស្តីពីការបញ្ចេញមតិ និងនីតិវិធីនៃការបោះឆ្នោតរបស់គណៈកម្មការប្រឹក្សាការងារ ។ ការសម្រេចរបស់គណៈកម្មការប្រឹក្សាការងារ ត្រូវធ្វើឡើងដោយយកតាមសម្លេងភាគច្រើននៃចំនួនសមាជិកដែលបានបោះឆ្នោត ។ ករណីទទួលបានសម្លេងស្មើគ្នា សម្លេងប្រធានមានឧត្តមានុភាព ។

**មាត្រា ៨.-**

កំណត់ហេតុនៃការប្រជុំត្រូវចុះហត្ថលេខាដោយប្រធាន និងអនុប្រធានគណៈកម្មការ ហើយត្រូវផ្ញើជូនសមាជិកពេញសិទ្ធិ និងសមាជិកបម្រុងទាំងអស់ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំ ។

**មាត្រា ៩.-**

គណៈកម្មការប្រឹក្សាការងារមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលរ៉ាប់រងដោយនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

អនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៨ និងអនុក្រឹត្យ ៣៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។៚

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងគ្រប់អង្គភាពវិជ្ជាជីវៈពាក់ព័ន្ធដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ល។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១១
- ឯកសារ - កាលប្បវត្តិ